# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ០៦៤ ប្រក.កសក

## ប្រកាស

### ស្តីពី

### ការរៀបចំគ្រប់គ្រង និងអភិរក្សសត្វខ្សឹប និងជីវចម្រុះនៃប្រព័ន្ធអេកូឡូស៊ីរួម ក្នុងភូមិសាស្ត្រ ខេត្តកំពង់ធំ និងខេត្តសៀមរាប

### រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តី ពីព្រៃឈើ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តី ពីជលផល

-បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាន នៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋាន ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួល អគ្គនាយកដ្ឋានចំការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា ប្រធានរដ្ឋបាលព្រៃឈើ

### សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងធ្វើការរៀបចំគ្រប់គ្រង និងអភិរក្សសត្វខ្សឹប និងជីវចម្រុះនៃប្រព័ន្ធអេកូឡូស៊ីរួម ក្នុង ភូមិសាស្ត្រ ស្រុកបារាយណ៍ ស្រុកស្ទោង ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ មានផ្ទៃក្រឡាទំហំ ២៦.៥២៣ (ម្ភៃប្រាំ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

មួយពាន់ប្រាំរយម្ភៃបី)ហិកតា និងស្រុកជីក្រែង ខេត្តសៀមរាប មានផ្ទៃក្រឡាទំហំ ៤.៦៣៦ (បួនពាន់ប្រាំមួយរយសាមសិបប្រាំមួយ)ហិកតា ដែលមានព្រំប្រទល់ជាប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចគោល និងមាននិយាមកាកំណត់លើផែនទីមាត្រដ្ឋាន ១:១០០.០០០ ដូចមានភ្ជាប់ជាមួយឧបសម្ព័ន្ធទី ១, ២, ៣, ៤ និងទី៥ នៃ ប្រកាសនេះ។

**ប្រការ២.–**

រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចរៀបចំគ្រប់គ្រង អភិរក្សសត្វខ្សឹប ជីវចម្រុះនៃប្រព័ន្ធអេកូឡូស៊ីរួម ក្នុងភូមិសាស្ត្រ ខេត្តកំពង់ធំ និងខេត្តសៀមរាបខាងលើ ដោយសហការជាមួយរដ្ឋបាលជលផល អគ្គនាយកដ្ឋានកសិកម្ម ក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន និងចាត់វិធានការគ្រប់គ្រងដូចខាងក្រោម :

- ការពារអភិរក្សសត្វខ្សឹប សត្វស្លាបផ្សេងទៀត ពិសេសប្រភេទជិតផុតពូជ ប្រភេទមានដោយកម្រ និងប្រភេទកំពុងទទួលរងគ្រោះថ្នាក់
- ការពារការហូរច្រោះ និងថែរក្សាប្រភពទឹក វាលស្មៅសម្រាប់សត្វពាហនៈព្រមទាំងរក្សាលំនឹងមជ្ឈដ្ឋានធម្មជាតិ ដែលជាទីជម្រកសម្រាប់ការស្នាក់អាស្រ័យសុខសាន្ត និងការបន្តពូជរបស់សត្វព្រៃនិងសត្វស្លាបគ្រប់ប្រភេទ ដើម្បីធានានិរន្តរភាពអេកូឡូស៊ីរួមនៃតំបន់ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម
- ការពារ និងទប់ស្កាត់ការជួញដូរ ការបរបាញ់ ការទាក់ចាប់ ការប្រមូលពងកូន ការបំពុលសត្វព្រៃគ្រប់ប្រភេទ
- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្របច្ចេកទេស អង្កេតតាមដានលក្ខណៈជីវសាស្ត្រសត្វព្រៃតាមដានបម្រែបម្រួលបរិស្ថាន រៀបចំទេសចរណ៍ធម្មជាតិ និងអនុវត្តសកម្មភាពផ្សេងទៀតដែលទាក់ទងជាមួយការអភិវឌ្ឍន៍ប្រកបដោយចីរភាព
- ផ្សព្វផ្សាយអប់រំ បណ្តុះបណ្តាលប្រជាកសិករ ក្នុងតំបន់អភិវឌ្ឍសហគមន៍ អនុវត្តប្រពលវប្បកម្មកសិកម្មតាមគោលការណ៍ធម្មជាតិ និងចូលរួមការងារអភិរក្សជីវចម្រុះក្នុងតំបន់
- កៀរគរជំនួយពីដៃគូអភិវឌ្ឍន៍ និងសប្បុរសជននានា ដើម្បីទ្រទ្រង់សកម្មភាពការពារ និងអភិរក្សនៃតំបន់។

**ប្រការ៣.–**

ត្រូវបានរក្សាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងសហគមន៍ជុំវិញដូចខាងក្រោម :

- ធ្វើនេសាទ និងវារីវប្បកម្មស្របតាមច្បាប់ស្តីពីជលផល
- ប្រើប្រាស់ដីធ្លីសម្រាប់ធ្វើស្រែ ដាំដំណាំគ្រប់ប្រភេទ ឬដាំវារីរុក្ខជាតិផ្សេងៗ
- រុករកផលអនុផលព្រៃលិចទឹកក្នុងតំបន់ដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ។

**ប្រការ៤.–**

ត្រូវបានហាមឃាត់រាល់សកម្មភាពទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងជីវចម្រុះដូចជា ការលើកទំនប់ ការជីកប្រឡាយ ការជីកអាងតម្កល់ទឹក ការប្រើប្រាស់ថ្នាំកសិកម្មខុសគោលការណ៍បច្ចេកទេស។

រាល់ការកែប្រែ ឬអភិវឌ្ឍទ្រង់ទ្រាយធំដែលនាំមកដល់ការបាត់បង់ជាមូលដ្ឋាននូវប្រព័ន្ធអេកូឡូស៊ីរួមនៃតំបន់ទាំងនេះ ត្រូវមានការសិក្សា វាយតម្លៃ និងសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២

**ប្រការ៥.-**

ដំណើរការរៀបចំគ្រប់គ្រងអភិរក្សសត្វខ្សឹប ជីវចម្រុះនៃប្រព័ន្ធអេកូឡូស៊ីរួមក្នុងភូមិសាស្ត្រ ខេត្តកំពង់ធំ និងខេត្តសៀមរាប ទាំងនេះ ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រដ្ឋបាលព្រៃឈើ ។

**ប្រការ៦.-**

ប្រកាស ឬសេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៧.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ ប្រធានមន្ទីរកសិកម្មខេត្តសៀមរាប និងប្រធាន អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០

**រដ្ឋមន្ត្រី**

ចាន់-សារុន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពង់ធំ និងសាលាខេត្តសៀមរាប
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

៣